# មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


០៣-៨-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៨០៥/៣៨៤ ស្តីពី ការតែងតាំងឯកឧត្តម **តក់ ថាវ** ជាទីប្រឹក្សាសម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា នីតិកាលទី ៣ មានឋានៈស្មើ **រដ្ឋលេខាធិការ** ៥០៦១

០៣-៨-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៨០៥/៣៨៥ ស្តីពីការតែងតាំងលោកជំទាវ **ចាប ជីវ័ន្ត** ជាទីប្រឹក្សាសម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា នីតិកាលទី ៣ ទទួលបន្ទុកកិច្ចការនារី មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ៥០៦២

០៥-៨-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៨០៥/៣៥៤ ស្តីពីការកែសម្រួល **គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ** ទៅជា **គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ** ដែលហៅកាត់ថា **គជបអ** ៥០៦៣

០៩-៨-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៨០៥/៣៦១ ស្តីពីការតែងតាំងឯកឧត្តម **ខៀវ ឡុង** ជាទីប្រឹក្សាឯកឧត្តម **ង៉ោ មុីនស្រ៊ុ** អនុប្រធានទី ២ ព្រឹទ្ធសភាទទួលបន្ទុកការងារសុខាភិបាលមានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ជំនួសឯកឧត្តម **ព្រុំ ចាន់នី** ៥០៦៧

០៩-៨-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៨០៥/៣៦៣ ស្តីពី ការតែងតាំងឯកឧត្តម **កែប ឆាយារ័ន្ត** ជាទីប្រឹក្សាសម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា នីតិកាលទី ៣ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ៥០៦៨

០៩-៨-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៨០៥/៣៦៩ ស្តីពី ការតែងតាំងឯកឧត្តម **អ៊ុក ខឿន** ជាជំនួយការផ្ទាល់សម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ៥០៦៩

១៩-៨-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៨០៥/៣៧០ ស្តីពី តម្លើងឋានន្តរស័ក្តិ ថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូននាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ចំនួន ០២ រូប ៥០៧០

២២-៨-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៨០៥/៣៧១ ស្តីពីការតែងតាំងលោកជំទាវ **ស៊ីវណ្ណា បុទុម** ជាឧបការីសម្តេចក្រុមព្រះ សហប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានឋានៈស្មើ **រដ្ឋលេខាធិការ** ៥០៧១

២២-៨-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៨០៥/៣៧៣ ស្តីពីការអនុញ្ញាតឱ្យអ្នកស្រី **ឡុង ស៊ីណែត** សញ្ជាតិ ខ្មែរ កើតនៅសង្កាត់ ច្បារអំពៅ ខណ្ឌមានជ័យ រាជធានីភ្នំពេញ លះបង់សញ្ជាតិខ្មែរ ដោយការស្ម័គ្រចិត្ត ៥០៧២

២២-៨-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៨០៥/៣៧៤ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ស៊ុម ម៉ូទៃហែនរី** ជនជាតិចិន សញ្ជាតិចិន កើតនៅទីក្រុងហុងកុង ប្រទេសចិន ៥០៧៣


## II-រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ


១៦-៨-២០០៥ -អនុក្រឹត្យលេខ ១០០ អនក្រ.បក ស្តីពីការធ្វើវិសោធនកម្មជំពូកទី ៤, ជំពូកទី ៥, ជំពូកទី ៦, ជំពូកទី ៧, ជំពូកទី ៨, ជំពូកទី ១៣ និង ជំពូកទី ១៥ នៃអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០១ ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅរបស់អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន ៥០៧៤

១៧-៨-២០០៥ -អនុក្រឹត្យលេខ ១០១ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៥០៨៤

១៧-៨-២០០៥ -អនុក្រឹត្យលេខ ១០២ អនក្រ.បកស្តីពីការប្រើប្រាស់គណនីឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ ៥០៨៦

១៧-៨-២០០៥ -អនុក្រឹត្យលេខ១០៣អនក្រ.បកស្តីពីការបន្ថែមឥណទានថវិកា ជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ៥០៨៨

២២-៨-២០០៥ -អនុក្រឹត្យលេខ ១០៤ អនក្រ.បក ស្តីពីការកែប្រែមាត្រា ២ នៃអនុក្រឹត្យស្តីពីការបង្កើតសភាពាណិជ្ជកម្មរាជធានីភ្នំពេញ ៥០៩០

២២-៨-២០០៥ -អនុក្រឹត្យលេខ ១០៥ អនក្រ.បកស្តីពីការបន្ថែមមុខងារ ភារកិច្ច ឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការ និងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និង មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ៥០៩៣

២៣-៨-២០០៥ -អនុក្រឹត្យលេខ ១០៦ អនក្រ.បកស្តីពីការកែសំរួលចំណុច "ក" និង "ខ" មាត្រា ៥៩ ថ្មីស្ទួន នៃអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៤ ស្តីពីការ កែសំរួលអនុក្រឹត្យ ស្តីពីអគ្រានុកូលដ្ឋាន ៥០៩៦

១៦-៨-២០០៥ -អនុក្រឹត្យលេខ ៦៨៣ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៥០៩៨
១៧-៨-២០០៥ -អនុក្រឹត្យលេខ ៦៨៤ អនក្រ.តត ស្តីពីការផ្ទេរភារកិច្ច និងការតែងតាំងមន្ត្រីរាជការ ៥០៩៩
១៧-៨-២០០៥ -អនុក្រឹត្យលេខ ៦៨៥ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៥១០១
១៩-៨-២០០៥ -អនុក្រឹត្យលេខ ៦៨៦ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៥១០២
១៩-៨-២០០៥ -អនុក្រឹត្យលេខ ៦៨៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥១០៣
១៩-៨-២០០៥ -អនុក្រឹត្យលេខ ៦៨៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥១០៤
១៩-៨-២០០៥ -អនុក្រឹត្យលេខ ៦៨៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥១០៥
១៩-៨-២០០៥ -អនុក្រឹត្យលេខ ៦៩០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥១០៦
១៩-៨-២០០៥ -អនុក្រឹត្យលេខ ៦៩១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥១០៧
១៩-៨-២០០៥ -អនុក្រឹត្យលេខ ៦៩២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥១០៨
១៩-៨-២០០៥ -អនុក្រឹត្យលេខ ៦៩៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥១០៩
១៩-៨-២០០៥ -អនុក្រឹត្យលេខ ៦៩៤ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៥១១០
២២-៨-២០០៥ -អនុក្រឹត្យលេខ ៦៩៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥១១១
២២-៨-២០០៥ -អនុក្រឹត្យលេខ ៦៩៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥១១២
២២-៨-២០០៥ -អនុក្រឹត្យលេខ ៦៩៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥១១៤
២២-៨-២០០៥ -អនុក្រឹត្យលេខ ៦៩៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥១១៥
២២-៨-២០០៥ -អនុក្រឹត្យលេខ ៦៩៩ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៥១១៦
២២-៨-២០០៥ -អនុក្រឹត្យលេខ ៧០០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥១២៩
២២-៨-២០០៥ -អនុក្រឹត្យលេខ ៧០១ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៥១៣១
២២-៨-២០០៥ -អនុក្រឹត្យលេខ ៧០២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥១៣៤
២២-៨-២០០៥ -អនុក្រឹត្យលេខ ៧០៣ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៥១៣៥
២២-៨-២០០៥ -អនុក្រឹត្យលេខ ៧០៤ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៥១៣៦
២៣-៨-២០០៥ -អនុក្រឹត្យលេខ ៧០៥ អនក្រ.តត ស្តីពីការតាំងស៊ប់ក្របខ័ណ្ឌមន្ត្រីក្រមការ ៥១៣៧
២៣-៨-២០០៥ -អនុក្រឹត្យលេខ ៧០៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥១៣៩


## ២-សេចក្តីសំរេច


១៩-៨-២០០៥ -សេចក្តីសំរេចលេខ ៣១ សសរ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំកិច្ចប្រជុំលើកទី ២ រវាងអភិបាលខេត្តជាប់ព្រំដែន កម្ពុជា វៀតណាម ៥១៤១

## III-ការងារបណ្ដាក្រសួង

### ១-ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


០២-៨-២០០៥ -ប្រកាសលេខ ៤០៣ សហវ ស្ដីពីការកែតំរូវប្រកាសលេខ ១៩៣ សហវ.ប្រក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥ ស្ដីពីការកំណត់សាធនភាពនៃក្រុមហ៊ុនធានារ៉ាប់រង ៥១៤៣

១១-៨-២០០៥ -ប្រកាសលេខ៤១៨សហវ.ប្រក ស្ដីពីការធ្វើប្រតិភូកម្មអំណាចជូន មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខេត្ត-ក្រុង ៥១៤៥

១០-៨-២០០៥ -សារាចរណែនាំលេខ០០៧សហវ.ពដ ស្ដីពីការអនុវត្តន៍ប្រកាសស្ដីពីការបន្ថរយៈពេលលើកលែងពន្ធលើប្រាក់ចំណេញពីរឆ្នាំ ចំពោះសហគ្រាសវិនិយោគផ្នែកវាយនភ័ណ្ឌបម្រើឱ្យការនាំចេញ ៥១៤៧


### ២-ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល


១៦-៨-២០០៥ -ប្រកាសលេខ ៦០៧ ឧរថ.កឧ.ប្រក ស្ដីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ដេ ហ្វាង ហ្គាមេន (DAE KWANG GARMENT CO.,LTD.) បង្កើតរោងចក្រ " កាត់ដេរសម្លៀកបំពាក់ " ដែលមានឈ្មោះថា "ដេ ហ្វាង ហ្គាមេន (DAE KWANG GARMENT " មានទីតាំងស្ថិតនៅ សួនឧស្សាហកម្មកាណាឌីយ៉ា អាគារលេខ ២៨ និង ២៩ ផ្លូវវែងស្រេង ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ៥១៤៩


### ៣-ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម


២៦-៧-២០០៥ -លិខិតលេខ ១៧១៣ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ស៊ី អាយ ចាង អ៊ីល មេនផៅវ័រ** ៥១៥១

២៦-៧-២០០៥ -លិខិតលេខ ១៧២១ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ចំការតែ គីរីរម្យ** ៥១៥៣

២៦-៧-២០០៥ -លិខិតលេខ ១៧២៣ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ចេង ហ៊ួត គូវ៉ាសេន** ៥១៥៥

២៦-៧-២០០៥ -លិខិតលេខ ១៧២៤ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ប៊ីលីស៍ ហ្វេមិលី ធួរ** ៥១៥៧

២៦-៧-២០០៥ -លិខិតលេខ ១៧២៥ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ធី.ជី.អេ.អេស ខបភើរេសិន** ៥១៥៩

២៦-៧-២០០៥ -លិខិតលេខ ១៧២៦ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ឆាយ៉ន អិចប្រេស** ៥១៦១

២៦-៧-២០០៥ -លិខិតលេខ ១៧២៧ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អេ អេ ស៊ី អាយ** ៥១៦៣

២៦-៧-២០០៥ -លិខិតលេខ ១៧២៨ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ធី ឃែម** ៥១៦៥

២៧-៧-២០០៥ -លិខិតលេខ ១៧២៩ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**វ៉ាណា ត្រាំវែល ធីអឹម** ៥១៦៧

២៧-៧-២០០៥ -លិខិតលេខ ១៧៣០ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ម៉ាក់ស៊ីម៉ា មីក្រូហិរញ្ញវត្ថុ** ៥១៦៨

២៧-៧-២០០៥ -លិខិតលេខ ១៧៣១ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**(ខេមបូឌា) អ៊ិនធីគ្រេធីត អ៊ិនជាស្ទ្រី** ៥១៧០

២៧-៧-២០០៥ -លិខិតលេខ ១៧៣២ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ពិសិដ្ឋអភិវឌ្ឍន៍សេដ្ឋកិច្ច លីមីតធីត** ៥១៧២

២៧-៧-២០០៥ -លិខិតលេខ ១៧៣៣ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ខេម ខេអេច អេឡិកត្រិក អ៊ិនជីនារីង** ៥១៧៣

២៧-៧-២០០៥ -លិខិតលេខ ១៧៣៤ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**បឌើរ គ្រុប** ៥១៧៥

២៨-៧-២០០៥ -លិខិតលេខ ១៧៤៤ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អី អេស អិល អេ (ខេមបូឌា)** ៥១៧៧

២៨-៧-២០០៥ -លិខិតលេខ ១៧៤៦ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អេស ស៊ី ជី ឌីស្កូវើរី ខូ អិលធីឌី** ៥១៧៩

០១-៨-២០០៥ -លិខិតលេខ ១៧៤៧ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ស្កាយ ជ្រេហ្គន ឌីវេឡុបមេន** ៥១៨១

០១-៨-២០០៥ -លិខិតលេខ ១៧៥០ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អំពិលផ្អែម ខមភេនី លីមីធីត** ៥១៨៥

០១-៨-២០០៥ -លិខិតលេខ ១៧៥៣ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អ៊ូរីផ្លេម អ៊ីមផត អិចផត** ៥១៨៧

០១-៨-២០០៥ -លិខិតលេខ ១៧៥៤ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ធី ខេ អាយ ស៊ី ខបភើរេសិន** ៥១៨៩

០១-៨-២០០៥ -លិខិតលេខ ១៧៥៥ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ហេង ដា អ៊ីមផត អិចផត** ៥១៩១

០១-៨-២០០៥ -លិខិតលេខ ១៧៥៦ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**បាដា អ៊ិនវេសមេន** ៥១៩៣

០១-៨-២០០៥ -លិខិតលេខ ១៧៥៧ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**វ៉ាល្យូមខូខូម៉ុ អ៊ីតែរីល (ខេមបូឌា) អ៊ិន** ៥១៩៥

០១-៨-២០០៥ -លិខិតលេខ ១៧៦៥ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**បានហេង អ៊ីមផត អិចផត & ខនស្ត្រាក់សិន** ៥១៩៧

០២-៨-២០០៥ -លិខិតលេខ ១៧៦៧ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**(ខេមបូឌា) ចុង កាង អ៊ិនធើណេសិនណល ត្រេឌីង** ៥១៩៩

០២-៨-២០០៥ -លិខិតលេខ ១៧៦៨ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**យូនៀន អហ្វ ហ្វ្រេន** ៥២០១

០២-៨-២០០៥ -លិខិតលេខ ១៧៧០ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អ៊ិនធើខម វៀលធី & ធួរ** ៥២០៣

០២-៨-២០០៥ -លិខិតលេខ ១៧៧២ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**មេគង្គ (ខេមបូឌា) អង្គរ ធួរ** ៥២០៥

០២-៨-២០០៥ -លិខិតលេខ ១៧៧៣ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អេ-បេច អ៊ិនធើប្រាយ ខមភេនី លីមីធីត** ៥២០៧

០២-៨-២០០៥ -លិខិតលេខ ១៧៧៤ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ប៉ារ៉ាមូវើរ ហ្វ្រេត អិចប្រេស** ៥២០៩

០២-៨-២០០៥ -លិខិតលេខ ១៧៨៤ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**កែវ ផល្លា អភិវឌ្ឍន៍** ៥២១១

០២-៨-២០០៥ -លិខិតលេខ ១៧៨៥ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ខេសៀរ ហ្គោមីង ខបភីរេសិន អិលធីឌី** ៥២១៣

០៣-៨-២០០៥ -លិខិតលេខ ១៧៩៨ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ទូង ប៊ី អ៊ិនធើធេនមេន** ៥២១៥

០៣-៨-២០០៥ -លិខិតលេខ ១៧៩៩ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ប្រសើររ័ត្ន ខបភើរេសិន** ៥២១៧

០៤-៨-២០០៥ -លិខិតលេខ ១៨០៤ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អង្គរ ឃីម គ្រេដ & ខបភើរេសិន** ៥២១៩

០៤-៨-២០០៥ -លិខិតលេខ ១៨០៥ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ខ្មែរ ខលឈ័រ ធួរ** ៥២២១

០៤-៨-២០០៥ -លិខិតលេខ ១៨០៨ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ណាទី ឌីវេឡុបមេន គ្រុប** ៥២២៣

០៤-៨-២០០៥ -លិខិតលេខ ១៨១៣ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ជី_ប៊ី_ស៊ី ខូ អិលធីឌី** ៥២២៥

០៤-៨-២០០៥ -លិខិតលេខ ១៨១៣ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ជី_ប៊ី_ស៊ី ខូ អិលធីឌី** ៥២២៥

០៤-៨-២០០៥ -លិខិតលេខ ១៨១៤ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អេស៊ាន ក្លីប គ្រុប ម៉ាស៊ីន ខូ អិលធីឌី** ៥២២៧

០៤-៨-២០០៥ -លិខិតលេខ ១៨១៥ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ស៊ី.អេ.ទី.ធី.ស៊ី.ឌី ខូ អិលធីឌី** ៥២២៩

០៥-៨-២០០៥ -លិខិតលេខ ១៨២៣ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អ៊ែត ហ្សស់ ខមម្យូនីខេសិន** ៥២៣១

០៥-៨-២០០៥ -លិខិតលេខ ១៨២៤ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អ៊ី អិក្ស_អិម (ខេមបូឌា)** ៥២៣៣

០៥-៨-២០០៥ -លិខិតលេខ ១៨២៥ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ទីង ស៊ុន គ្រុប អ៊ីមផត អិចផត** ៥២៣៥

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៥/៣៤៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រតនត្តយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៣ នៃរដ្ឋសភា នាថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ និង ថ្នាក់ដឹកនាំរដ្ឋសភា និង សំដែងការទុកចិត្ត ទៅលើសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចក្រុមព្រះ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម គត់ ថាវ ជាទីប្រឹក្សាសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ព្រះប្រធានរដ្ឋសភា នីតិកាលទី៣ មានឋានៈស្មើ រដ្ឋលេខាធិការ ។

មាត្រា ២ : ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ឱ្យបានសំរេច។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល.០៥០៨.៣៦៥

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០០៥*

លេខៈ ៣៣៩ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ ៨ ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

...ណ្ឌី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៥/៣៤៥

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/001 ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៣ នៃរដ្ឋសភា នាថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ និង ថ្នាក់ដឹកនាំរដ្ឋសភា និង សំដែងការទុកចិត្ត ទៅលើសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចក្រុមព្រះ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងលោកជំទាវ ចាប ជីវ័ន្ត ជាទីប្រឹក្សាសម្តេចក្រុមព្រះ នរោត្តម រណឬទ្ធិ ព្រះប្រធានរដ្ឋសភា នីតិកាលទី៣ ទទួលបន្ទុកកិច្ចការនារី មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា ២ : ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ឱ្យបានសម្រេច ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧៤.០៥០៨.៣៦៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០០៥

លេខ ៣៣ ច.ល
បានឃើញ និងចម្លងត្រឹមត្រូវតាមច្បាប់ដើម
រាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ២០០៥
រដ្ឋលេខាធិការរាជរដ្ឋាភិបាល

ស៊ុំ ម៉ាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៥/៣៥៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/០៩ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលស្នើសុំរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** កែសម្រួល **គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ** ទៅជា **គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ** ដែលហៅកាត់ថា **គជបអ** និងជាអក្សរឡាតាំង ហៅកាត់ថា NCONIF ជាស្ថាប័នជាតិចំណុះផ្ទាល់រាជរដ្ឋាភិបាល ។

**មាត្រា ២ :** កែសម្រួលសមាសភាពគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ដោយរក្សាឋានៈបច្ចុប្បន្ន មានដូចខាងក្រោម :

| | | |
|---|---|---|
| ១- | សម្តេចចៅហ្វាវាំង វរវៀងជ័យ អធិបតីស្រីធ្គារ **គង់ សំអុល** | ប្រធាន |
| ២- | ឯកឧត្តម សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ | អនុប្រធាន |
| ៣- | ឯកឧត្តម **មិន ឃិន** | អនុប្រធាន អចិន្ត្រៃយ៍ |
| ៤- | ឯកឧត្តម **ជា សុខុម** | សមាជិក អចិន្ត្រៃយ៍ |

៥- ឯកឧត្តម **ខា សាន** សមាជិក អចិន្ត្រៃយ៍

៦- ឯកឧត្តម **ញ៉ែម ម៉ាលី** សមាជិក អចិន្ត្រៃយ៍

៧- ឯកឧត្តម រដ្ឋលេខាធិការ ០១ រូប តំណាង ក្រសួងព្រះបរមរាជវាំង សមាជិក

៨- ឯកឧត្តម រដ្ឋលេខាធិការ ០១ រូប តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៩- ឯកឧត្តម រដ្ឋលេខាធិការ ០១ រូប តំណាង ក្រសួងការពារជាតិ សមាជិក

១០- ឯកឧត្តម រដ្ឋលេខាធិការ ០១ រូប តំណាង ក្រសួងមហាផ្ទៃ សមាជិក

១១- ឯកឧត្តម រដ្ឋលេខាធិការ ០១ រូប តំណាង ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

១២- ឯកឧត្តម រដ្ឋលេខាធិការ ០១ រូប តំណាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

១៣- ឯកឧត្តម រដ្ឋលេខាធិការ ០១ រូប តំណាង ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក

១៤- ឯកឧត្តម រដ្ឋលេខាធិការ ០១ រូប តំណាង ក្រសួងអប់រំ យុវជន និងកីឡា សមាជិក

១៥- ឯកឧត្តម រដ្ឋលេខាធិការ ០១ រូប តំណាង ក្រសួងសុខាភិបាល សមាជិក

១៦- ឯកឧត្តម រដ្ឋលេខាធិការ ០១ រូប តំណាង ក្រសួងធម្មការ និងសាសនា សមាជិក

១៧- ឯកឧត្តម រដ្ឋលេខាធិការ ០១ រូប តំណាង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

១៨- ឯកឧត្តម រដ្ឋលេខាធិការ ០១ រូប តំណាង ក្រសួងពត៌មាន សមាជិក

១៩- ឯកឧត្តម រដ្ឋលេខាធិការ ០១ រូប តំណាង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ សមាជិក

២០- ឯកឧត្តម អគ្គស្នងការរង ០១ រូប តំណាង អគ្គស្នងការនគបាលជាតិ សមាជិក

២១- ឯកឧត្តម អគ្គមេបញ្ជាការរង ០១ រូប តំណាង អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ សមាជិក

២២- ឯកឧត្តម អនុរដ្ឋលេខាធិការ ០១ រូប តំណាង រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សមាជិក

២៣- តំណាង ក្រសួង ស្ថាប័ន ពាក់ព័ន្ធ សមាជិក

២៤-ឯកឧត្តម-លោក អភិបាលរង ខេត្ត-ក្រុង ០១ រូប សមាជិក

**មាត្រា ៣ :** គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ មានតួនាទី និងភារកិច្ច លើកគំរោងផែនការ ស្តីអំពីរូបភាពចាត់តាំង តំណាងអោយពិធីការរដ្ឋ ក្នុងការរៀបចំកម្មវិធី និងគ្រប់គ្រងពិធីបុណ្យផ្សេងៗ ដូចជាបុណ្យប្រពៃណីជាតិ បុណ្យជាតិ បុណ្យអន្តរជាតិ ទទួលជូនដំណើរភ្ញៀវជាន់ខ្ពស់ជាតិ និងអន្តរជាតិ តាមការកំណត់របស់អង្គការនីតិប្បញ្ញត្តិ នីតិប្រតិបត្តិ និងព្រះមហាក្សត្រ ។

**មាត្រា ៤ :** អនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ មានភារកិច្ចរៀបចំបទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ តាមការណែនាំរបស់ប្រធាន ។

មាត្រា ៥ : ប្រធាន គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ មានសិទ្ធិលើកសំណើជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងសំរេចការស្នើសុំតែងតាំង ឬផ្លាស់ប្តូរ ទីប្រឹក្សា និងជំនួយការអមគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ។

មាត្រា ៦ : គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ មានអនុប្រធានអចិន្ត្រៃយ៍ ០១រូប អមដោយសមាជិកអចិន្ត្រៃយ៍មួយចំនួនជាជំនួយការ ដឹកនាំចាត់ចែងការងារទូទៅរបស់គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ។

មាត្រា ៧ : អនុប្រធាន សមាជិកអចិន្ត្រៃយ៍ និងសមាជិកគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធានអចិន្ត្រៃយ៍ ។

មាត្រា ៨ : គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ មានអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិមួយ ជាអង្គភាពចំណុះប្រតិបត្តិផ្ទាល់ ដែលត្រូវបានដឹកនាំដោយអគ្គលេខាធិការមួយរូប និងមានអគ្គលេខាធិការរងមួយចំនួន ជាជំនួយការ ។ សមាសភាពថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ដែលមានស្រាប់រួមមាន :

១- ឯកឧត្តម មិន យិន អគ្គលេខាធិការ គ.ជ.ប.អ

២- ឯកឧត្តម ជា សុខុម អគ្គលេខាធិការរងទី១ គ.ជ.ប.អ

៣- ឯកឧត្តម ជា គាន អគ្គលេខាធិការរង គ.ជ.ប.អ

៤- ឯកឧត្តម ញ៉ែម ម៉ាលី អគ្គលេខាធិការរង គ.ជ.ប.អ

៥- ឯកឧត្តម រស់ គខំ អគ្គលេខាធិការរង គ.ជ.ប.អ

៦- ឯកឧត្តម ឈិន កេតនា អគ្គលេខាធិការរង គ.ជ.ប.អ

អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ដំណើរការការងាររបស់ខ្លួនដោយរក្សាឋានៈបច្ចុប្បន្នរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការដែលមានស្រាប់ ។

មាត្រា ៩ : ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ប្រើប្រាស់រចនាសម្ព័ន្ធ អនុក្រឹត្យដែលមានស្រាប់ ។

មាត្រា ១០ : គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ មានសិទ្ធិប្រើប្រាស់ត្រាផ្ទាល់ខ្លួន ដើម្បីបំពេញការងាររបស់ខ្លួន ។

មាត្រា ១១ : គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ បំពេញការងារដោយប្រើប្រាស់ថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី និងអាចទទួលនូវជំនួយឧបត្ថម្ភផ្សេងៗ ពីអង្គការជាតិ-អន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និងអង្គភាពជំនាញនានា ដើម្បីគាំទ្រដល់ការរៀបចំពិធីបុណ្យនីមួយៗ ។

**មាត្រា ១២** : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានភារកិច្ចអនុវត្តឱ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ១៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
**នរោត្តម សីហមុនី**

នស.០៨០៥.៣៧៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៥ ខែសីហា ឆ្នាំ ២០០៥

លេខ : ៣២៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

សាខី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៥/៣៦១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចប្រធានព្រឹទ្ធសភា

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំងឯកឧត្តម **ខៀវ ឡុង** ជាទីប្រឹក្សាឯកឧត្តម **ម៉ៅ ម៉ុនស៊្រី** អនុប្រធានទី២ ព្រឹទ្ធសភា ទទួលបន្ទុកការងារ សុខាភិបាល មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ជំនួសឯកឧត្តម **ញ៉ុំ ចាន់នី** ។

**មាត្រា ២:** ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល-០៥០៥-៣៨២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០០៥

លេខ : ៣៣៥ ច.ល
**ជូនចំពោះទុក**
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ[illegible] ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណាឌី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៥/៣៦៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៣ នៃរដ្ឋសភា នាថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ និង ថ្នាក់ដឹកនាំរដ្ឋសភា និង សំដែងការទុកចិត្ត ទៅលើសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចក្រុមព្រះ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម កែប ឆាយរ័ត្ន ជាទីប្រឹក្សាសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ព្រះប្រធានរដ្ឋសភា នីតិកាលទី៣ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា ២ :** ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ឱ្យបានសំរេច។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរស.០៥០៨.៣៨៤

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០០៥*

លេខ: ៣៣២ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ៨ ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សរ៉ាឌី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៥/៣៦៩

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចប្រធានព្រឹទ្ធសភា

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំងឯកឧត្តម អ៊ុក ឿន ជាជំនួយការផ្ទាល់សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២:** ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រ.ល.០៥០៥.៣៩០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០០៥

លេខ : ៣៦៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ៧ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
សាអ៊ី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៥/៣៧០

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១:** តម្លើងឋានន្តរស័ក្តិ ថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូននាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ចំនួន ០២រូប ដូចមានរាយនាមខាងក្រោម :

១-វរសេនីយ៍ឯក **ឡោក ម៉ូរ** អត្តលេខ ០១១០០៥

២-វរសេនីយ៍ឯក **ឡាច វ៉ាន់** អត្តលេខ ០០៣៣៨៥

**មាត្រា២:** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះឱ្យបានសំរេច ។

**មាត្រា៣:** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៥

**ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

៣រស-០៥០៩.៣៩១

លេខ: ៣៤២ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ,ថ្ងៃទី ២៥ ខែ ៨ ៧ ឆ្នាំ២០០៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សាឌី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៥/៣៧១

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : ត្រូវបានតែងតាំងលោកជំទាវ **ស៊ីវណ្ណ បុទុម** ជាឧបការីសម្តេចក្រុមព្រះ សហប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

**មាត្រា២** : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៥

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

៣.ល.០៥០៨.៣៩២

លេខៈ ១៤០ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ,ថ្ងៃទី ២៥ ខែ០៧ ឆ្នាំ២០០៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណាំ តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៥/ ៣៧៣

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរិវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : អនុញ្ញាតឱ្យអ្នកស្រី **ឡុង ស៊ីណែត** ( LONG SINET ) សញ្ជាតិ ខ្មែរ កើតថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៨០ នៅសង្កាត់ ច្បារអំពៅ ខណ្ឌ មានជ័យ រាជធានីភ្នំពេញ បច្ចុប្បន្នស្នាក់នៅ APT-BLK 469B ADMIRALTY DRIVE#16-67 Singapore752469 លះបង់សញ្ជាតិខ្មែរ ដោយការស្ម័គ្រចិត្ត របស់សាមីខ្លួន ។

**មាត្រា២** : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី២៧ ខែ សីហា ឆ្នាំ ២០០៥

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

៣រល-០៥០៨.៣៩៤

លេខ : ៣៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ,ថ្ងៃទី ២៥ ខែ ៨ ឆ្នាំ២០០៥

អគ្គលេខាធិការរាជរដ្ឋាភិបាល

ណាទី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៥/ ៣៧៤

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក ស៊ុម ប៉ូវៃហេនរី ( SHUM PO WEI HENRY ) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី ១៨ ខែមីនា ឆ្នាំ ១៩៧៤ នៅទីក្រុងហុងកុងប្រទេសចិន។

**មាត្រា២** : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី២២ ខែ សីហា ឆ្នាំ ២០០៥

ភ្លូចព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

៣រល.០៥០៥.៣៩៥

លេខ : ៩៣១ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ,ថ្ងៃទី ២៥ ខែ [illegible] ឆ្នាំ២០០៥

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] ឌី តាន់

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១០០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## វិសោធនកម្មជំពូកទី ៤, ជំពូកទី ៥, ជំពូកទី ៦, ជំពូកទី ៧, ជំពូកទី ៨, ជំពូកទី ១៣ និង ជំពូកទី ១៥ នៃអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០១ ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅរបស់អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦០ ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៥/២៦៥ ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥ ស្តីពី វិសោធនកម្មមាត្រា ៤, មាត្រា ១០, និង មាត្រា ១៣ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦០ ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា មួយ :**

ជំពូកទី ៤. ជំពូកទី ៥. ជំពូកទី ៦. ជំពូកទី ៧. ជំពូកទី ៨. ជំពូកទី ១៣ និង ជំពូកទី ១៥ នៃអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន ត្រូវធ្វើវិសោធនកម្មដូចតទៅ ÷

## ជំពូកទី ៤ ថ្មី
## អគ្គលេខាធិការ

**មាត្រា ៦ ថ្មី :**

អគ្គលេខាធិការ មានភារកិច្ចចាំបាច់ដូចតទៅ :

៦.១. គ្រប់គ្រងចាត់ចែង និង ដឹកនាំការងារប្រចាំថ្ងៃរបស់ "អាជ្ញាធរ" និង សំរបសំរួលរាល់ការងារសកម្មភាពកំចាត់មីនរបស់អង្គការប្រតិបត្តិករទាំងអស់ និង សហគមន៍ម្ចាស់ជំនួយ ជំនួសមុខឱ្យ "អាជ្ញាធរ"។ អគ្គលេខាធិការ មានអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់ជាជំនួយការ។ អគ្គលេខាធិការត្រូវ រាយការណ៍ជូនប្រធាន និង អនុប្រធាន "អាជ្ញាធរ" ។

៦.២. រៀបចំការប្រជុំឱ្យបានទៀងទាត់ជាមួយបណ្តាអង្គការប្រតិបត្តិករ ដែលធ្វើប្រតិបត្តិការសកម្មភាព មីននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

៦.៣. រៀបចំអង្គប្រជុំអោយបានទៀងទាត់ជាមួយភ្នាក់ងារផ្តល់ជំនួយ ដើម្បីធានានូវគោលនយោបាយសំរបសំរួល និង ពង្រឹងភាពជាដៃគូ ។

៦.៤. ចាត់ចែង និងចេញបញ្ជាចំណាយនានា តាមគំរោងថវិកាដែលបានអនុម័ត ហើយនឹងគ្រប់គ្រងលើរាល់ចំណូល-ចំណាយប្រចាំឆ្នាំរបស់ "អាជ្ញាធរ" ។

# ជំពូកទី ៥ ថ្មី

## អគ្គលេខាធិការដ្ឋាន

**មាត្រា ៧ ថ្មី:**

៧.១. អគ្គលេខាធិការដ្ឋានត្រូវស្ថិតក្រោមការដឹកនាំគ្រប់គ្រងរបស់អគ្គលេខាធិការ ។

ដើម្បីធានាឱ្យមានប្រសិទ្ធភាព និង សុក្រឹតភាពការងារខ្ពស់របស់ "អាជ្ញាធរ" អគ្គលេខាធិការដ្ឋាន មាននាយកដ្ឋាន ចំនួនប្រាំមួយ សំរាប់បំរើការងារតាមមុខងារដូចតទៅ :

៧.១.១. បទប្បញ្ញត្តិ និង ត្រួតពិនិត្យ

៧.១.២. ផែនការ សេដ្ឋកិច្ចសង្គម និង គ្រប់គ្រងទិន្នន័យ

៧.១.៣. សង្គ្រោះជនពិការដោយសារមីន

៧.១.៤. ទំនាក់ទំនងសាធារណៈ

៧.១.៥. រដ្ឋបាល-បុគ្គលិក និង ភស្តុភារ

៧.១.៦. ហិរញ្ញវត្ថុ

៧.២. អគ្គលេខាធិការដ្ឋាន ត្រូវប្រព្រឹត្តទៅតាមបទបញ្ជាផ្ទៃក្នុង ដែលអនុម័តដោយគណៈអចិន្ត្រៃយ៍ "អាជ្ញាធរ" ។

**មាត្រា ៨ :**

អគ្គលេខាធិការដ្ឋានត្រូវមានត្រាមួយដោយឡែករបស់ខ្លួន ។

**មាត្រា ៩ :**

នាយកដ្ឋាន ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប ព្រមទាំងសហការីមួយចំនួនជាជំនួយការ ។ ប្រធាននាយកដ្ឋានត្រូវតែងតាំងដោយអនុក្រឹត្យ ។

**មាត្រា ១០:**

១០.១.បុគ្គលិកដែលបំរើការឱ្យអគ្គលេខាធិការដ្ឋាន មានពីរប្រភេទ : មន្ត្រីរាជការផ្ទេរមកពីក្រសួង ឬ ស្ថាប័នរដ្ឋនានា និង បុគ្គលិកជាប់កិច្ចសន្យា ។ បុគ្គលិកទាំងពីរប្រភេទនេះ ត្រូវឆ្លងកាត់ការប្រលងជ្រើសរើសប្រកបដោយតម្លាភាព និងប្រសិទ្ធភាពខ្ពស់ ដោយផ្អែកលើសមត្ថភាពទេពកោសល្យ និង បទពិសោធន៍ការងារ ។

១០.២.ចំពោះបុគ្គលិកដែលជាមន្ត្រីរាជការ នៃក្រសួង ឬ ស្ថាប័ននានាដែលមានបំណងចង់មកបំរើការនៅអគ្គលេខាធិការដ្ឋាន ត្រូវឆ្លងកាត់ការប្រលងប្រកួតសមត្ថភាព មុននឹងស្នើរសុំ ផ្ទេរក្របខ័ណ្ឌ និង ភារកិច្ចរបស់ខ្លួន ។

១០.៣.បទបញ្ជាផ្ទៃក្នុងនៃការគ្រប់គ្រងការងារបុគ្គលិក ត្រូវស្ថិតនៅក្នុងលក្ខខ័ណ្ឌការងារដោយឡែក ដែលកំណត់ដោយសេចក្តីសំរេចរបស់គណៈអចិន្ត្រៃយ៍ " អាជ្ញាធរមីន" ។

## ជំពូកទី ៦ ថ្មី
## នាយកដ្ឋានបទប្បញ្ញត្តិ និង ត្រួតពិនិត្យ

### មាត្រា ១១ ថ្មី :

នាយកដ្ឋានបទប្បញ្ញត្តិ និង ត្រួតពិនិត្យ មានភារកិច្ចដូចតទៅ :

១១.១. រៀបចំ និង ពិនិត្យឯកសារកិច្ចព្រមព្រៀងសំរាប់ចុះហត្ថលេខារវាង "អាជ្ញាធរ" និង ម្ចាស់ជំនួយ

១១.២. រៀបចំនីតិវិធីនានា និង ដាក់ឱ្យដំណើរការ នូវការផ្តល់ប័ណ្ណទទួលស្គាល់ និងអាជ្ញាប័ណ្ណដល់គ្រប់អង្គការប្រតិបត្តិករជាតិ និង អន្តរជាតិ ភ្នាក់ងារឯកជន ដែលអនុវត្តសកម្មភាពមីនក្នុងព្រះរាជាណាចក្រកម្ពុជា ហើយដំណើរការនេះ ត្រូវប្រព្រឹត្តទៅប្រកបដោយភាពត្រឹមត្រូវ និង មានតម្លាភាព ។

១១.៣. រៀបចំស្តង់ដាបច្ចេកទេស នីតិវិធី គោលការណ៍ ថវិកា និង បទប្បញ្ញត្តិទាំងឡាយដែលទាក់ទងទៅនឹងការធ្វើផែនការសកម្មភាពមីន និង ការគ្រប់គ្រងព័តិមានបច្ចេកទេស

១១.៤. គ្រប់គ្រងរាល់ការប្រើប្រាស់ ដឹកជញ្ជូន បែងចែក និង ស្តុកទុកនូវគ្រាប់រំសេវ និងគ្រឿងផ្ទុះរបស់ប្រតិបត្តិករសកម្មភាពមីននានា

១១.៥. រៀបចំកិច្ចដំណើរការ ដើម្បីចេញបញ្ជាអោយកំទេចចោលគ្រាប់មីនគ្រប់ប្រភេទប្រឆាំងមនុស្ស រថក្រោះ និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ដែលរកឃើញដោយរាល់ប្រតិបត្តិករសកម្មភាពមីន ហើយដែលអាជ្ញាធរមានសមត្ថកិច្ចមិនកាន់កាប់ និង មិនប្រើប្រាស់

១១.៦. រៀបចំចេញផ្សាយនូវស្តង់ដាបច្ចេកទេស នីតិវិធី គោលការណ៍ បទប្បញ្ញត្តិនានា ដែលទាក់ទងនឹងសកម្មភាពមីន

១១.៧. រៀបចំ ប្រមូលផ្តុំឯកសារ និង អនុសាសន៍នានា សំរាប់ "អាជ្ញាធរ" ធ្វើការដកហូតនូវប័ណ្ណទទួលស្គាល់ពីអង្គការប្រតិបត្តិករជាតិ និងអន្តរជាតិ ដែលធ្វើសកម្មភាពមីនក្នុងព្រះរាជាណាចក្រកម្ពុជា

១១.៨. ត្រួតពិនិត្យការអនុវត្តន៍នូវច្បាប់ស្តីពីការហាមប្រាមការប្រើប្រាស់គ្រាប់មីនគ្រប់ប្រភេទប្រឆាំងមនុស្ស និង សន្ធិសញ្ញាអូតាវ៉ាស្តីពីការហាមប្រាមការប្រើប្រាស់ ការរក្សាទុក ការផលិត និងការផ្ទេរមីនប្រឆាំងមនុស្ស ហើយនិងការបំផ្លាញមីនទាំងនោះចោល ។

១១.៩. ត្រួតពិនិត្យរាល់ប្រតិបត្តិការសកម្មភាពមីន ដើម្បីធានាឱ្យការអនុវត្តន៍ប្រព្រឹត្តទៅតាមស្តង់ដាជាតិ និង អន្តរជាតិ ស្តីពីសកម្មភាពមីន

## ជំពូកទី ៧ ថ្មី
## នាយកដ្ឋានផែនការ សេដ្ឋកិច្ចសង្គម និង គ្រប់គ្រងទិន្នន័យ

### មាត្រា ១២ ថ្មី:

នាយកដ្ឋានផែនការ សេដ្ឋកិច្ចសង្គម និង គ្រប់គ្រងទិន្នន័យមានភារកិច្ចដូចតទៅ :

១២.១. រៀបចំផែនការជាតិសកម្មភាពមីន (របាយការណ៍ពាក់ព័ន្ធ និងជាបន្តបន្ទាប់តាមពេល) រួមមាន:

១២.១.១. រៀបចំផែនការយុទ្ធសាស្ត្រ ៥ ឆ្នាំ នៃសកម្មភាពមីន និង សកម្មភាពទ្រទ្រង់ផ្សេងៗ

១២.១.២. ពិនិត្យ និងជ្រើសរើសគំរោងស្នើដោយផ្អែកលើផែនការសកម្មភាពដែលទាក់ទងទៅនឹងបញ្ហាមីន/យុទ្ធភណ្ឌមិនទាន់ផ្ទុះដែលភាគីពាក់ព័ន្ធនានាដាក់ជូនមកដើម្បីផ្ញើទៅម្ចាស់ជំនួយ

១២.១.៣. រៀបចំយុទ្ធសាស្ត្រផ្សេងៗ និងឯកសារប្រហាក់ប្រហែលដទៃទៀតដែលទាក់ទងទៅនឹងផែនការជាតិក្នុងការគ្រប់គ្រងលើវិស័យសកម្មភាពមីន

១២.២. គ្រប់គ្រង និង រៀបចំមូលដ្ឋានទិន្នន័យប្រមូលផ្តុំនូវរាល់ឯកសារទាក់ទងនឹងសកម្មភាពមីន ដែលបានចុះបញ្ជី និង រក្សាទុក

១២.៣. សហការជាមួយភ្នាក់ងារបោសសំអាតមីនទាំងឡាយ ដើម្បីធានាដំណើរការប្រកបដោយគុណភាពនូវការផ្លាស់ប្តូរព័ត៌មានទាំងក្នុង និងក្រៅប្រទេស និង ត្រួតពិនិត្យទៅតាមផែនការជាតិស្តីពីសកម្មភាពមីន

១២.៤. ជួយក្នុងកិច្ចសំរបសំរួលជាមួយម្ចាស់ជំនួយ ភ្នាក់ងារអភិវឌ្ឍន៍ជាតិ និង អន្តរជាតិ ប្រទេសនានា ស្ថាប័នរដ្ឋ និង អាជ្ញាធរពាក់ព័ន្ធ ភ្នាក់ងារឯកជន ដើម្បីរៀបចំផែនការសកម្មភាពជាយុទ្ធសាស្ត្រ ធានាឱ្យមានភាពរីកចំរើនជឿនលឿនដល់គំរោងការអភិវឌ្ឍន៍ក្នុងប្រទេសកម្ពុជា ហើយដែលត្រូវបាន និង កំពុងអនុវត្តក្នុងបរិយាកាសប្រកបដោយសុវត្ថិភាពខ្ពស់

១២.៥. តាមដាន និង សំរបសំរួលលើសកម្មភាពការងារសេដ្ឋកិច្ច សង្គម ដែលបង្កើតដោយអនុក្រឹត្យលេខ ៧០អនក្រ/បក.ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៤ ស្តីពីការគ្រប់គ្រងកិច្ចប្រតិបត្តិការបោសសំអាតមីន ដើម្បីរួមចំណែកអភិវឌ្ឍន៍ សេដ្ឋកិច្ច-សង្គម

## ជំពូកទី ៨ ថ្មី

## នាយកដ្ឋានសង្គ្រោះជនពិការដោយសារមីន

**មាត្រា ១៣ ថ្មី:**

នាយកដ្ឋានសង្គ្រោះជនពិការដោយសារមីន មានភារកិច្ចដូចតទៅ :

១៣.១. តាមដានការងារសង្គ្រោះជនរងគ្រោះដោយសារមីនជាមួយភ្នាក់ងារពាក់ព័ន្ធផ្សេងៗ មាន ក្រសួង សង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ក្រុមប្រឹក្សាសកម្មភាពជនពិការ និង ស្ថាប័នជាតិ ក៏ដូចជាអន្តរជាតិនានា ដែលមានការពាក់ព័ន្ធ ។ ការគ្រប់គ្រង ការសម្របសម្រួល និង ការឃ្លាំមើលលើកិច្ចសង្គ្រោះជនពិការដោយសារមីនភាគច្រើន គឺជាការទទួលខុសត្រូវរបស់អង្គការក្រុមប្រឹក្សាសកម្មភាពជនពិការ និង អង្គការពាក់ព័ន្ធនានា ។ អង្គការទាំងនោះត្រូវផ្តល់ជូន "អាជ្ញាធរ" នូវផែនការយុទ្ធសាស្ត្រនៃសកម្មភាពការងារ និង របាយការណ៍រីកចំរើន ស្តីពីសកម្មភាពសង្គ្រោះជនពិការដោយសារមីន

១៣.២. ធ្វើការទំនាក់ទំនងជាមួយភ្នាក់ងារ និង អង្គការពាក់ព័ន្ធនានា ដើម្បីស្រង់យកព័ត៌មានស្តីពីស្ថិតិ និង អត្រាគ្រោះថ្នាក់ និង សេវាកម្មពាក់ព័ន្ធនានា

១៣.៣. ទទួលរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និង ឆ្នាំ ពីអង្គការជាតិ និង អន្តរជាតិ ដែលពាក់ព័ន្ធ ទៅនឹងកិច្ចសង្គ្រោះជនពិការដោយសារមីន

១៣.៤. ធ្វើសេចក្ដីរាយការណ៍រីកចំរើនប្រចាំខែ ត្រីមាស ឆមាស និង ឆ្នាំ ស្ដីពីសកម្មភាពសង្គ្រោះជនពិការដោយសារមីន ជូនអគ្គលេខាធិការ ។

## ជំពូកទី ១៣ ថ្មី
## យន្តការរៀបចំផែនការ ការត្រួតពិនិត្យ ការអនុវត្តន៍ និង ការគ្រប់គ្រងវិន័យ

**មាត្រា ២១ ថ្មី:**

២១.១. ការរៀបចំផែនការយុទ្ធសាស្ត្រដែលជាចក្ខុវិស័យរយៈពេលវែង នៃសកម្មភាពមីន ក្នុងព្រះរាជាណាចក្រកម្ពុជា ជាភារកិច្ចរបស់ "អាជ្ញាធរ" ។ ដើម្បីញ៉ាំងឱ្យខ្លឹមសារនៃផែនការជាយុទ្ធសាស្ត្រនេះគ្របដណ្ដប់បានគ្រប់ជ្រុងជ្រោយ "អាជ្ញាធរ" ត្រូវបង្កើតគណៈកម្មការពិគ្រោះមួយដែលមានសមាសភាពដូចតទៅ :

- តំណាងក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- តំណាងក្រសួងការពារជាតិ
- តំណាងក្រសួងមហាផ្ទៃ
- តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- តំណាងអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ/បញ្ជាការដ្ឋានកងវិស្វកម្ម
- តំណាងក្រសួងអភិវឌ្ឍន៍ជនបទ
- តំណាងក្រសួងផែនការ
- តំណាងក្រសួង សង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា
- តំណាងក្រសួងសាធារណការ និង ដឹកជញ្ជូន
- តំណាងក្រសួងធនធានទឹក និង ឧតុនិយម
- តំណាងក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

- តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- តំណាងក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- តំណាងគណៈកម្មាធិការជាតិទទួលបន្ទុកកិច្ចការព្រំដែន
- តំណាងអគ្គស្នងការនគរបាលជាតិ
- តំណាងអាជ្ញាធរអប្សរា
- តំណាងអង្គការប្រតិបត្តិករជាតិ និង អន្តរជាតិ ដែលពាក់ព័ន្ធនឹងសកម្មភាពមីន
- តំណាងម្ចាស់ជំនួយ

២១.២. តម្រូវការ និងនីតិវិធីចាំបាច់នានា ដែលទាក់ទងនឹងការអភិវឌ្ឍន៍ផែនការយុទ្ធសាស្ត្ររបស់ជាតិ នឹងត្រូវចែងលំអិតក្នុងគោលនយោបាយដោយឡែកដែលចេញដោយ "អាជ្ញាធរ" ។

មាត្រា ២២ :

ផែនការជាយុទ្ធសាស្ត្រនេះ បន្ទាប់ពីទទួលបានការអនុម័តពីនាយករដ្ឋមន្ត្រី នឹងត្រូវចូលជាធរមានក្នុងរយៈពេលមួយសប្តាហ៍បន្ទាប់ពីថ្ងៃចុះហត្ថលេខា ។ ផែនការជាយុទ្ធសាស្ត្រនេះគឺជាផែនការរបស់រាជរដ្ឋាភិបាលដែលរាល់បណ្តាអង្គការប្រតិបត្តករជាតិ និង អន្តរជាតិ ត្រូវយកជាមូលដ្ឋានគោលសំរាប់រៀបចំ ឬ សម្របសម្រួលផែនការរបស់ខ្លួន ។

មាត្រា ២៣ :

អង្គការប្រតិបត្តិករជាតិ និង អន្តរជាតិសកម្មភាពមីនទាំងអស់ ត្រូវរៀបចំផ្ញើផែនការរយៈពេលខ្លី ឬ រយៈពេលវែងរបស់ខ្លួន មកអគ្គលេខាធិកាដ្ឋាន ដើម្បីបញ្ចូលជាមួយផែនការមេ របស់ជាតិ ។

មាត្រា ២៤ :

ប្រតិបត្តករទាំងអស់ ចាំបាច់ត្រូវអនុវត្តសកម្មភាពទៅតាមផែនការដែលបានអនុម័តហើយ ។ អគ្គលេខាធិការដ្ឋាន "អាជ្ញាធរ" ត្រូវមានភារកិច្ចត្រួតពិនិត្យឱ្យបានទៀងទាត់ ដើម្បីធានាការអនុវត្តន៍ឱ្យចំទិសដៅ ពិសេសស្របទៅនឹងផែនការជាតិ ។

មាត្រា ២៥ :

អគ្គលេខាធិការដ្ឋាន "អាជ្ញាធរ" ជាមជ្ឈមណ្ឌលជាតិទទួលបន្ទុកគ្រប់គ្រងទិន្នន័យនៃសកម្មភាព មីន នៅព្រះរាជាណាចក្រកម្ពុជា។ រាល់បណ្តាអង្គការប្រតិបត្តិករទាំងអស់ទាំងសកម្មភាពមីន និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះត្រូវធ្វើសេចក្តីរាយការណ៍អោយបានទៀងទាត់ប្រចាំត្រីមាស ឆមាស និងឆ្នាំ

មកអគ្គលេខាធិការដ្ឋាន ។ ខ្លឹមសារនៃសេចក្តីរាយការណ៍ ត្រូវមានយ៉ាងហោច សកម្មភាព លទ្ធផលនៃកម្មវិធីនិមួយៗ របាយការណ៍ហិរញ្ញវត្ថុ និង ព័ត៌មានស្តីពីស្ថានភាព សេដ្ឋកិច្ច-សង្គម ។ តំរូវការចាំបាច់នានាសំរាប់រាយការណ៍ និង ការធ្វើរបាយការណ៍ នឹងមានចែងលំអិតក្នុងគោលនយោបាយដោយឡែក ដែលចេញដោយ "អាជ្ញាធរ" ។

**មាត្រា ២៦ :**

ក្រោយពីបានទទួលការសំរេចជាគោលការណ៍ពីគណៈអចិន្ត្រៃយ៍ "អាជ្ញាធរ" អគ្គលេខាធិការមានសិទ្ធិចុះកិច្ចសន្យាបន្តទៅក្រុមហ៊ុន ឬ ភ្នាក់ងារដែលមានសមត្ថភាពដទៃទៀត ដើម្បីទទួលភារកិច្ចផ្ទាល់របស់ខ្លួន ។ នីតិវិធីនៃការចុះកិច្ចសន្យាបន្ត ត្រូវអនុវត្តទៅតាមនីតិវិធី និង គោលការណ៍លទ្ធកម្មរបស់រាជរដ្ឋាភិបាល ។

## ជំពូកទី ១៥ ថ្មី

## យន្តការគ្រប់គ្រងសេវាកម្ម កិច្ចសង្គ្រោះជនរងគ្រោះដោយសារមីន

**មាត្រា ២៩ ថ្មី:**

រាល់ការគ្រប់គ្រង តាមដាន ត្រួតពិនិត្យសេវាកម្ម និង ការសម្របសម្រួលកិច្ចសង្គ្រោះជនពិការដោយសារមីន ជាភារកិច្ចរបស់ "អាជ្ញាធរ" ។ ដោយយន្តការផ្នែកនេះមានដំណើរការហើយ "អាជ្ញាធរ" ប្រគល់ភារកិច្ចសំរបសំរួលនេះទៅក្រសួង សង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា និង អង្គការក្រុមប្រឹក្សា សកម្មភាពជនពិការ តាមរយៈការទទួលស្គាល់នូវប្រកាសលេខ ៣០៨ ក.ស.ប.យ. ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៩ ។ "អាជ្ញាធរ" អាចផ្តល់អនុសាសន៍ចំពោះរាល់សកម្មភាពសង្គ្រោះជនពិការដោយសារមីន និង ក្នុងករណីចាំបាច់ "អាជ្ញាធរ" អាចបញ្ជូនតំណាងរបស់ខ្លួនឱ្យទៅចូលរួមក្នុងប្រតិបត្តិការសង្គ្រោះនោះជាមួយអង្គការ និង ភ្នាក់ងារទាំងឡាយដែលទទួលបន្ទុកការងារនេះ ។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ត្រូវធ្វើរបាយការណ៍រីកចំរើនប្រចាំត្រីមាស ឆមាស និង ឆ្នាំ មក "អាជ្ញាធរ" អោយបានទៀងទាត់ ។

**មាត្រា ពីរ :**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៩ :

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ រដ្ឋមន្ត្រីក្រសួង សង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រី និង រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួនឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៥

**ហ៊ុន សែន**

**ចម្លងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៩
- រាជកិច្ច
- កាលប្បវត្តិ - ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១០១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម នស/រកម/០៧០៤/០០១.ចុះថ្ងៃទី១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យ នស/រកត/០៧០៤/១១៧ .ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤.ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស /៩៤.ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ .ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣.ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ .ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥. ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៤/០០២. ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥

-បានឃើញអនុក្រឹត្យលេខ ៩២ អនក្រ.បក.ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៤ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូកនៃច្បាប់ស្តីអំពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៥

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ១.៨៧៥ លានរៀល (មួយពាន់ប្រាំបីរយចិតសិបប្រាំលានរៀលគត់) ពីជំពូក ៤០ (ចំណាយផ្សេងៗ) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក ១១ (ចំណាយដំណើរការរដ្ឋបាលសំភារៈ និង ការផ្គត់ផ្គង់តូច) ជូនគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រភេទ កថាខ័ណ្ឌ និង អនុកថាខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា សភានីតិកាលទី ២ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៦ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែសីហា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីគោរពជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់
រដ្ឋមន្ត្រីស្តីទី
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១០៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការប្រើប្រាស់គណនី ឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ

---

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១/នស /៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ ស្តីពីវិសោធនកម្ម មាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០២/០២១ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៣
- បានឃើញអនុក្រឹត្យលេខ ៣៨ អនក្រ ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៩៥ ស្តីពីបែបបទនៃឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ

- បានឃើញប្រកាសរបស់រាជរដ្ឋាភិបាល ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៤ ស្តីពីឯកជនភាវូបនីយកម្ម សហគ្រាសសាធារណៈ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំ រេ ច

**មាត្រា១ :** អនុញ្ញាតអោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រើប្រាស់គណនី " ឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ " ដែលត្រូវបានបង្កើតឡើងតាមមាត្រា ៨៣ នៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ មានទឹកប្រាក់សរុបចំនួន **៨២៥.៧០០** ដុល្លារអាមេរិក ( ប្រាំបីរយម្ភៃប្រាំពាន់ប្រាំពីររយដុល្លារអាមេរិក ) ដែលបានមកពីការដោះដូរដីធ្លី និង ភូមិគ្រឹះចំនួន ០៥ ពីក្រសួងការពារជាតិ លើមុខសញ្ញាចំណាយសងថ្លៃសំណង់អគារអគ្គបញ្ជាការដ្ឋានថ្មី ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និង រដ្ឋមន្ត្រីក្រសួង-ស្ថាប័នពាក់ព័ន្ធមានភារៈកិច្ចអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ [illegible] ឆ្នាំ ២០០៥

ហ៊ុន សែន

ចំលងជូន :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ២
- កាលប្បវត្តិ-ឯកសារ

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១០៣ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការបន្ថែមឥណទានថវិកា

## ជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ . ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧ . ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ . ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ . ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ . ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ .ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស ៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៤/០០២ . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៥
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក . ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៩២ អនក្រ.បក . ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៤ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋ តាមជំពូកនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៥
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ដោយអនុលោមទៅតាមមាត្រា ៤៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០១/នស/៩៣. ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ត្រូវបានអនុញ្ញាតផ្តល់បន្ថែមឥណទានថវិកា ចំនួន ៦.០៦៨.០០០.០០០ រៀល ( ប្រាំមួយពាន់ ហុកសិបប្រាំបីលានរៀលគត់ ) ទៅលើសៀវភៅថវិកា របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥ ។

**មាត្រា២:** ឥណទានថវិកាបន្ថែមដូចបានកំណត់ក្នុងមាត្រា ១ ខាងលើ ត្រូវបានបន្ថែមនៅជំពូក ៣១ ( អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ ) ជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ផ្តល់ជូនមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ខេត្ត សៀមរាប សំរាប់បើកបៀវត្សជូន ជនបាត់បង់សមត្ថភាពការងារ ជនពិការ និង និវត្តជន ដែលជាយោធិនរំសាយពីក្រសួងការពារជាតិ ។

**មាត្រា៣:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា៤:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- កាលប្បវត្តិ - ឯកសារ

**បានយកសេចក្តីជំរាបជូន**

**សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**រដ្ឋមន្ត្រីស្តីទី**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ១០៤ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការកែប្រែមាត្រា ២ នៃអនុក្រឹត្យស្តីពី ការបង្កើតសភាពាណិជ្ជកម្មរាជធានីភ្នំពេញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៣ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសភាពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៦១ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតសភាពាណិជ្ជកម្មរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ១៩៩៨ ស្តីពីការកែប្រែមាត្រា២នៃអនុក្រឹត្យ ស្តីពីការបង្កើតសភាពាណិជ្ជកម្មរាជធានីភ្នំពេញ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សម្រេច

**មាត្រា១** .-

មាត្រា ២ថ្មី នៃអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ១៩៩៨ ស្តីពីការកែប្រែ មាត្រា២ នៃអនុក្រឹត្យលេខ ៦១ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត សភាពាណិជ្ជកម្មរាជធានីភ្នំពេញ ត្រូវបានកែសម្រួលដូចតទៅ ៖

**មាត្រា ២ ថ្មី** ៖ សភាពាណិជ្ជកម្មរាជធានីភ្នំពេញ មានសមាជិកជ្រើសតាំងចំនួន ៤០ រូប (សែសិប) ដែលជ្រើសរើសតាមការបោះឆ្នោត ស្របតាមលក្ខខណ្ឌដែលបានកំណត់ដោយអនុក្រឹត្យ ដោយឡែក ហើយត្រូវបានបែងចែកតាមប្រភេទអាជីវកម្មនីមួយៗ ដូចតទៅ ៖

| | |
|---|---|
| ១-ប្រភេទពាណិជ្ជកម្ម | ១២ រូប |
| ២-ប្រភេទឧស្សាហកម្ម និងសិប្បកម្ម | ១២ រូប |
| ៣-ប្រភេទសេវាកម្ម និងវិជ្ជាជីវៈសេរី | ១០ រូប |
| ៤-ប្រភេទកសិកម្ម | ០៦ រូប |

**មាត្រា ២** .-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលរាជធានីភ្នំពេញ និងប្រធានសភាពាណិជ្ជកម្មរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ាជរដ្ឋាភិបាលកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ១០៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបន្ថែមមុខងារ ភារកិច្ច ឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និង មជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

* * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការប្តូរឈ្មោះនាយកដ្ឋានរុក្ខា-ប្រមាញ់ ទៅជារដ្ឋបាលព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តា ស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## សម្រេច

**មាត្រា ១.-**

ត្រូវបានបន្ថែមមុខងារភារកិច្ច ត្រួតពិនិត្យសុវត្ថិភាពចំណីអាហារ នៃផលិតផលកសិកម្មទាំងឡាយចាប់ពីការផ្តើមផលិតដាំដុះរហូតដល់តំណាក់កាលចុងក្រោយ នៃការកែច្នៃបឋម ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង

នេសាទ និងត្រូវបានបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការ និង ស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និង មជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

អង្គការលេខថ្មី របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ២.-**

អង្គភាពដែលមានភារកិច្ច អនុវត្តមុខងារភារកិច្ចបន្ថែមដូចមានចែងក្នុងមាត្រា ១ នៃអនុក្រឹត្យនេះ និងសកម្មភាពពាក់ព័ន្ធ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៣.-**

នាយកដ្ឋានផែនការ និង ស្ថិតិ មានភារកិច្ច ÷

- វិភាគ និងកសាងផែនការអភិវឌ្ឍន៍វិស័យកសិកម្មរយៈពេលខ្លី មធ្យម និងវែង និងតាមដានការអនុវត្ត
- ដឹកនាំអនុវត្តការអង្កេតទូទៅ ការអង្កេតតាមផ្នែករបស់វិស័យកសិកម្ម ប្រមូលព័ត៌មាន ស្ថិតិកសិកម្ម វិភាគវាយតម្លៃ និងចងក្រងឯកសារ
- រៀបចំ កសាងកម្មវិធីវិនិយោគសាធារណៈ និងរៀបចំតម្រង់ទិសកម្មវិធីវិនិយោគឯកជនក្នុងវិស័យកសិកម្ម និងកម្មវិធីអភិវឌ្ឍន៍គោលដៅអាហារូបត្ថម្ភ
- ស្រាវជ្រាវ និង ផ្សព្វផ្សាយអំពីថ្លៃកសិផល និងតម្រូវការផលិតផលកសិកម្មគ្រប់ប្រភេទ នៅទីផ្សារក្នុងស្រុក និងទីផ្សារអន្តរជាតិ សម្រាប់កសិករងាយស្រួលជ្រើសរើសធ្វើផលិតកម្មកសិកម្ម
- ទំនាក់ទំនងសហការជាមួយស្ថាប័ននានាក្នុងក្របខ័ណ្ឌការងារវិនិយោគនិងគម្រោងផែនការ ដែលពាក់ព័ន្ធទៅនឹងវិស័យកសិកម្ម
- ទទួលភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន ។

**មាត្រា ៤.-**

នាយកដ្ឋាន សហប្រតិបត្តិការអន្តរជាតិ មានភារកិច្ច ÷

- សម្របសម្រួល និងទំនាក់ទំនងការងារជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- រៀបចំគម្រោងសហប្រតិបត្តិការទ្វេភាគី និង ពហុភាគី ជាមួយអន្តរជាតិដែលពាក់ព័ន្ធនឹងវិស័យកសិកម្ម តាមគោលការណ៍របស់រាជរដ្ឋាភិបាល
- រៀបចំសំណុំឯកសារផ្សេងៗ ដែលពាក់ព័ន្ធនឹងកិច្ចការអន្តរជាតិ ជូនថ្នាក់ដឹកនាំក្រសួងសម្រាប់ចរចា និងចុះហត្ថលេខាលើកំណត់ហេតុ អនុស្សារណៈ ពិធីសារ និងកិច្ចព្រមព្រៀងផ្សេងៗ
- គ្រប់គ្រង និងសម្របសម្រួលរាល់សកម្មភាពគ្រប់អង្គភាព ដែលដំណើរការក្រោមឥណទានរបស់ជំនួយទ្វេភាគី ពហុភាគី ជាមួយរាជរដ្ឋាភិបាល ឬជាមួយក្រសួង ស្ថាប័ននានា
- តាមដាន និងវាយតម្លៃលើការអនុវត្តរាល់ខ្លឹមសារពាក់ព័ន្ធជាមួយវិស័យកសិកម្មដែលបានចែងក្នុងកំណត់ហេតុ អនុស្សារណៈ ពិធីសារ អនុសញ្ញា សន្ធិសញ្ញា និងកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខា
- ចងក្រង និងគ្រប់គ្រងទិន្នន័យ ឯកសារដែលទាក់ទងនឹងកិច្ចការអន្តរជាតិ លើវិស័យកសិកម្ម
- ទទួលភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន ។

**មាត្រា ៥.-**

មជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម មានភារកិច្ច ÷

- ប្រមូលចងក្រង និងរក្សាទុកនូវ លិខិតបទដ្ឋាន ឯកសារ ព្រឹត្តិប័ត្រ និងអត្ថបទនានាដែលពាក់ព័ន្ធដល់ការ

គ្រប់គ្រងស្រាវជ្រាវគោលនយោបាយកម្មវិធី ផែនការ ស្ថិតិ និងទិន្នន័យបម្រើឱ្យកិច្ចអភិវឌ្ឍន៍វិស័យកសិកម្ម និង សេដ្ឋកិច្ច ។

- ផ្តល់ព័ត៌មាន និងទិន្នន័យកសិកម្មដល់អតិថិជន ដែលមានជាអាទិ៍ អ្នកសិក្សាស្រាវជ្រាវ សិស្ស និស្សិត ភ្នាក់ងារឯកជន ស្ថាប័នរដ្ឋ និងដៃគូអភិវឌ្ឍន៍ តាមរយៈការអាន និងសិក្សានៅនឹងកន្លែង និងតាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង

- ធ្វើការចងក្រង ផ្សព្វផ្សាយ និងធ្វើបច្ចុប្បន្នភាព នូវសមិទ្ធផលកសិកម្ម លិខិតបទដ្ឋាន គោលនយោបាយ បេសកកម្ម រចនាសម្ព័ន្ធគ្រប់គ្រង និងសមាសភាពថ្នាក់ដឹកនាំនៃក្រសួង តាមរយៈគេហទំព័ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

- ទទួលភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូន ។

មជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ដឹកនាំដោយប្រធានមួយរូប ថ្នាក់ស្មើប្រធាននាយកដ្ឋាន និង អនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ។

**មាត្រា ៦.-**

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ទទួលបន្ទុកអនុវត្តភារកិច្ចតាមអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និង សហគ្រាសសាធារណៈ ។

**មាត្រា ៧.-**

ក្រៅពីអនុក្រឹត្យថ្មីនេះ និងក្រៅពីមាត្រា ១០ ខ្លឹមសារ នៃអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅរក្សាជាធរមានដដែល ។

**មាត្រា ៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២ ខែ ៣ ឆ្នាំ ២០០៥*

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចក្នុងមាត្រា ៨
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធអនុក្រឹត្យលេខ ..១១៥... អនក្រ.បក ចុះថ្ងៃទី២៦ខែ [illegible] ឆ្នាំ ២០០៥

**អង្គការលេខរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១០៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសំរួលចំណុច "ក" និង "ខ" មាត្រា ៥៩ថ្មីស្ទួន នៃអនុក្រឹត្យ លេខ ១៧ អនក្រ.បក ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៤ ស្តីពីការកែសំរួលអនុក្រឹត្យ ស្តីពីអត្រានុកូលដ្ឋាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីអត្រានុកូលដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីការកែសំរួលមាត្រា ៨ និង មាត្រា៥៩ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០០ ស្តីពីអត្រានុកូលដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៤ ស្តីពីការកែសំរួលអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រាតែមួយ ..**

កែសំរួលចំណុច "ក" និង "ខ" មាត្រា ៥៩ថ្មីស្ទួន នៃអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ២០០៤ ស្តីពីការកែសំរួលអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន មានដូចខាងក្រោម :

**មាត្រា៥៩ថ្មីស្ទួន ..**

**ក.** ការសុំបញ្ជាក់អត្រានុកូលដ្ឋានមាន ចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់អាពាហ៍ពិពាហ៍ សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់មរណភាព ត្រូវបានអនុវត្តចំពោះតែលើពលរដ្ឋខ្មែរ ចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០២ រហូតដល់ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៦ ។

ផុតរយៈពេលនេះ ពលរដ្ឋខ្មែរដែលគ្មានសំបុត្រអត្រានុកូលដ្ឋានកំណើត និង មរណភាព ត្រូវទៅសុំសំបុត្រអត្រានុកូលដ្ឋាន តាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា២៥ថ្មី និង មាត្រា៤០ថ្មី នៃអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៤ ស្តីពីការកែសំរួល អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន ។ ចំពោះអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ អនុញ្ញាតអោយរឹងសុំចុះតាមការស្ម័គ្រចិត្តនៃសហព័ទ្ធ ។

**ខ.**ចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន រហូតដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៦ ប្រជាពលរដ្ឋខ្មែរដែលបានមកចុះសៀវភៅអត្រានុកូលដ្ឋាន រួមមាន បញ្ជាក់កំណើត និង បញ្ជាក់មរណភាព នឹងត្រូវផ្តល់ជូនសំបុត្រអត្រានុកូលដ្ឋានខាងលើនេះនូវច្បាប់ដើម ០១សន្លឹកដោយឥតគិតថ្លៃ។

ចំពោះទារកដែលបានកើតក្នុងចន្លោះពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០២ ដល់ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០០៦ ហើយដែលមិនទាន់បានចុះសៀវភៅអត្រានុកូលដ្ឋានកំណើតនៅពេលដែលឪពុក ឬ ម្តាយ ឬ អាណាព្យាបាល មកសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើត អោយទាន់ពេលមិនហួសពីថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៦ នឹងត្រូវបានផ្តល់ជូនសំបុត្រអត្រានុកូលដ្ឋានកំណើតច្បាប់ដើម ០១ សន្លឹកដោយឥតគិតថ្លៃ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ សី.៣ ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចម្លងជូន :**

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួងស្ថាប័ន
- គ្រប់សាលាខេត្ត ក្រុង
- ឯកសារ កាលប្បវត្តិ

បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

**សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង នរោត្តម សិរីវុឌ្ឍ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ**...៦៨៣...អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

**ស ម្រេ ច**

**មាត្រា ១** : ត្រូវបានតែងតាំងលោក **អ៊ិត ចាន់ឡុង** ឋានន្តរសក្តិរៈមន្ត្រីថ្នាក់លេខ ៥ ជាប្រធាននាយកដ្ឋានផ្ទៃក្នុង នៃទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៥*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច និង ឯកឧត្តមឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ_កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ៦៧៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់ក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានផ្ទេរភារកិច្ចអភិបាលស្រុក ចំនួន ០៣រូប ក្នុងខេត្តកោះកុង ដូចមានរាយនាមខាងក្រោម :

១- លោក **ម៉ឿង លួនសា** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ៥ ពីអភិបាល ស្រុកមណ្ឌលសីមា ឱ្យមក បំរើការងារនៅសាលាខេត្តកោះកុង ដោយរក្សាឋានន្តរសក្តិ និងថ្នាក់ដដែល ។

២- លោក **ស៊ុន គៀន** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ៧ ពីអភិបាល ស្រុកគិរីសាគរ ទៅជាអភិបាល ស្រុកមណ្ឌលសីមា

៣- លោក **ឈេង ធី** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ៧ ពីអភិបាល ស្រុកបុទុមសាគរ ទៅជាអភិបាល ស្រុកគិរីសាគរ ។

**មាត្រា ២ :** ត្រូវបានតែងតាំងលោក **អន តារៈ** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ១២ ជាអភិបាលស្រុកបុទុមសាគរ ខេត្តកោះកុង ។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ . ថ្ងៃទី ១៧ ខែ ៨ ឆ្នាំ ២០០៥*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>**ចម្លងជូន**</u> :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (<u>ដើម្បីជូនជ្រាប</u>)*
- *ដូចមាត្រា ៤ (<u>ដើម្បីអនុវត្ត</u>)*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ [illegible]

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

៣ល

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ៈ** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សប្ញទ្ធិ** ជូនលោកព្រិន្ទបាលឯក **ហ្វ្រង់ក បេណូយស្តែល** ( Adjudant-Chef Franck BENOISTEL ) ជំនួយការ និងជាលេខារបស់អនុព័ន្ធយោធាបារាំងប្រចាំ ព្រះរាជាណាចក្រកម្ពុជា ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា២ៈ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងសហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួលៈ**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
SR.156 -ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៧៧៦ អនក្រ-បក

## អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ១០២ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០០១ ស្តីពីការតម្លើងនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ទៅជាអគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រង ការអនុវត្តន៍ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ៩០ អនក្រ.បក ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៥ ស្តីពីការតម្លើងការិយាល័យអាស៊ាន និង ការិយាល័យទំនាក់ទំនងអន្តរជាតិ ទៅជានាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

### សម្រេច

**មាត្រា ១ :** ត្រូវបានប្រគល់ភារកិច្ចជូនមន្ត្រីរាជការ នៃក្រសួងបរិស្ថាន ដូចមានរាយនាមខាងក្រោម ៖

១_លោក ថ្មឿន សុខា អោយបំពេញមុខងារ ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេស

២_លោក សែម ស៊ុនដារ៉ា អោយបំពេញមុខងារ ជាប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ

៣_លោក ខួន គង់ អោយបំពេញមុខងារ ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេស

៤_លោក កែ ចន្ទ្រមុន្នីរដ្ឋានា អោយបំពេញមុខងារ ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៥*

ហ៊ុន សែន

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច និង ឯកឧត្តមឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *ឯកសារ_កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

១៧៧

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសមាគម OMIYA CITY ROTARY CLUB ដែលបានឧបត្ថម្ភទឹកប្រាក់ ចំនួន ២៦.១៨០ ដុល្លារអាមេរិក សំរាប់ជួយសាងសង់អគារសិក្សា ០១ខ្នង មាន០៥ បន្ទប់ បំពាក់ដោយសម្ភារៈគ្រប់ប្រភេទ នៅសាលាបឋមសិក្សាសែនសុខ-សម្បឹម ក្នុងឃុំសែនសុខ ស្រុកក្រឡាញ់ ខេត្តសៀមរាប ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា និង អភិបាលខេត្តសៀមរាប ត្រូវ អនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។ X+

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ស្រាវណ៍ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

SR.125

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...១១៧...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៣៧

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយសិរីវឌ្ឍនស្ថាបនាជាតិ** ជូនលោកស្រី HOSHINO MIYUKI សញ្ជាតិជប៉ុន ដែលបានបរិច្ចាគថវិកា តាមរយៈអង្គការ *សន្តិសុខគ្រិស្តប្រទេសជប៉ុន* នូវទឹកប្រាក់ ចំនួន ២.៩៣២,២៣ ដុល្លារអាមេរិក សំរាប់ជួយសាងសង់អគារសិក្សា ០១ខ្នង បំពាក់ដោយសម្ភារៈគ្រប់គ្រាន់ បង្គន់អនាម័យ ០១ខ្នង និង អណ្តូងទឹក០១ នៅសាលាបឋមសិក្សាទំពេជ្រ ក្នុងភូមិទំពេជ្រ ឃុំទ្រា ស្រុកស្ទោង ខេត្តកំពង់ធំ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា និង អភិបាលខេត្តកំពង់ធំ ត្រូវ អនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច

SR.136 - ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៦៨៣.......អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៣៧

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា

**សម្រេច**

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសមាគម CHISAN ROTARY KAI ដែលបានឧបត្ថម្ភថវិកា ចំនួន ២៧.០៧២ ដុល្លារ សំរាប់ជួយសាងសង់អគារសិក្សា ០១ខ្នង មាន០៥ បន្ទប់ ខ្លោងទ្វារ សម្ភារៈ ក្តារខៀន តុ កៅអី សំរាប់គ្រូ និងសិស្ស នៅសាលាបឋមសិក្សាព្រៃទទឹង ក្នុងឃុំសំរោងយា ស្រុកពួក ខេត្តសៀមរាប ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា និង អភិបាលខេត្តសៀមរាប ត្រូវ អនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

SR.123

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧៩០ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៙

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសមាជិក ០៥រូប នៃអង្គការ Happy Tree ដែលបានផ្តល់ថវិកាជួយជួសជុលអាគារជម្ងឺឆ្លង នៃ មន្ទីរពេទ្យព្រះកេតុមាលា ព្រមទាំងបំពាក់សម្ភារៈបរិក្ខារផ្សេងៗ ចំណាយអស់ទឹកប្រាក់ សរុបចំនួន ៩០.០៩១.៥០ ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោមនេះ :-

| | | | | |
|---|---|---|---|---|
| ១-លោក | **ជើរី វង្ស** | **(Jerry Wong)** | ប្រធានអង្គការ | **Happy Tree** |
| ២-លោកស្រី | **អាដា ចាក់** | **(Ada Chak )** | អនុប្រធានអង្គការ | **Happy Tree** |
| ៣-លោកស្រី | **អានីតា ផាក់** | **(Anita Pak )** | អនុប្រធានអង្គការ | **Happy Tree** |
| ៤-លោកស្រី | **ម៉ារីយ៉ា យូ** | **(Maria Yu )** | លេខាធិការ | **Happy Tree** |
| ៥-លោកស្រី | **អាដា លឿង** | **(Ada Leung )** | ហិរញ្ញិក | **Happy Tree** |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងសហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៥*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
SR.138 -ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧៩១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ពាបនាជាតិ

៙

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

**សម្រេច**

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ពាបនាជាតិ** ជូនសប្បុរសជន ចំនួន០៤រូប ដែលបានជួយដល់សមាគម នៃជនពិការភ្នែកកម្ពុជា សំរាប់អភិវឌ្ឍន៍ និង បណ្តុះបណ្តាលជនពិការភ្នែក អោយមានមុខជំនាញ និងមុខរបរត្រឹមត្រូវ ដោយចំណាយអស់ទឹកប្រាក់សរុប ចំនួន ៣៧១.៧៦៥ ដុល្លារ ដូចមានរាយនាមខាងក្រោម :-

**ក-មេដាយមាសស្ពាបនាជាតិ :**

១-លោក Ube Sasakawa ប្រធានមូលនីធិ ជប៉ុន

២-លោក Suchi Ono នាយកប្រតិបត្តិ មូលនីធិជប៉ុន

**ខ-មេដាយប្រាក់ស្ពាបនាជាតិ :**

១-លោក MAKATO ITOH ប្រធានក្រុមហ៊ុន MARUBUNI THAILAND,CO.LTD

២-លោក ម៉ុន ម៉ៅ នាយកប្រតិបត្តិសមាគម នៃជនពិការភ្នែកកម្ពុជា

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវអនុវត្ត អនុក្រឹត្យ នេះអោយទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៥*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
SR.123 -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៩៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៣៧

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសមាគម VOLUNTEER KOBUNOKAI នៅប្រទេសជប៉ុន ដែលបានផ្តល់ថវិកា ចំនួន ១៦.៧៦០ ដុល្លារអាមេរិក សំរាប់ជួយសាងសង់អគារ សិក្សា ០១ខ្នង មាន០៣ បន្ទប់ បំពាក់ដោយសម្ភារីមគ្រប់គ្រាន់ បង្គន់អនាម័យ ០១ខ្នង និង អណ្តូងទឹក០១ នៅសាលា បឋមសិក្សា សុជល ក្នុងភូមិសុជុល ឃុំផាន់ញើម ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា និង អភិបាលខេត្តកំពង់ធំ ត្រូវ អនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ.ថ្ងៃទី ២៨ ខែ ៧ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

SR.132

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤៨៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៚

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ០១គ្រឿង ជូនវត្ត HOKOJI TEMPLE នៅប្រទេសជប៉ុន ដែលបានផ្តល់ថវិកា ចំនួន ១៧.០៣៤.៥៦ ដុល្លារអាមេរិក សំរាប់ជួយសាងសង់អគារ សិក្សា ០១ខ្នង មាន០៣បន្ទប់ បំពាក់ដោយសង្ហារឹមគ្រប់គ្រាន់ បង្គន់អនាម័យ ០១ខ្នង និង អណ្តូងទឹក០១ នៅសាលាបឋមសិក្សាស្វាយ ក្នុងភូមិស្វាយ ឃុំស្រើង ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា និង អភិបាលខេត្តកំពង់ធំ ត្រូវ អនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច

SR.134 -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៧៥៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការ តែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ** ជូនមន្ត្រីរាជការ ចំនួន០២រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ច លើវិស័យវប្បធម៌ និង វិចិត្រសិល្បៈ ដូចមានរាយនាមខាងក្រោមនេះ :-

១-លោក **ម៉ែន ផាត** ព្រឹទ្ធបុរសមហាវិទ្យាល័យដូរ្យតន្ត្រីនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

២-លោក **ឃុន សារម៉ែន** ប្រធាននាយកដ្ឋានសារមន្ទីរ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ,ថ្ងៃទី ១៩ ខែ ៧ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

Ps-149

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ....៧៣៥...អនក្រ.បក -៩៩

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលរាជធានីភ្នំពេញ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនដល់ទីប្រឹក្សាបច្ចេកទេសអន្តរជាតិ ចំនួន០៤រូប ដែលបានចូលរួមយ៉ាងសកម្មលើការអនុវត្តគោលនយោបាយកាត់បន្ថយភាពក្រីក្រ និងកែលំអបរិស្ថានរបស់រាជរដ្ឋាភិបាលកម្ពុជា នៅក្នុងរាជធានីភ្នំពេញ ចំណាយអស់ថវិកាចំនួន ១.២៦០.០០០ ដុល្លារ ដូចមានរាយនាមខាងក្រោម :-

| | |
|---|---|
| ១-Mr. Januar Hakim | អ្នកជំនាញការអភិវឌ្ឍន៍ទីក្រុង នៃធនាគារអភិវឌ្ឍន៍អាស៊ី ADB |
| ២-Mr. Wan Maung | ទីប្រឹក្សាបច្ចេកទេស គំរោង នៃ (JFPR) : CAM-9023 |
| ៣-Mr. Ramesh B Munankami | ទីប្រឹក្សាបច្ចេកទេស នៃគំរោងភាពជាដៃគូ ក្នុងការកាត់បន្ថយភាពក្រីក្រក្នុងទីក្រុង |
| ៤-Ms. Som Sook | លេខាធិការអង្គការ ACHR |

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ៧ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

B.tha.38

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧៩៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និង ជូនសប្បុរសជន ចំនួន០៥រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងព្រះវិហារ និង ប៉ុស្តិ៍សុខភាព នៅក្នុងខេត្តកំពង់ឆ្នាំង ដូចមានរាយព្រះនាម និងនាមខាងក្រោមនេះ :-

**ក.មេដាយមាសស្ថាបនាជាតិ :**

១-ព្រះតេជគុណ **នុត ហាយ** ចៅអធិការវត្ត ឧទុម្ពរ ហៅ វត្តក្រាំងល្វា ជួយកសាងព្រះវិហារ វត្តឧទុម្ពរ ឃុំក្រាំងល្វា ស្រុកសាមគ្គីមានជ័យ បច្ច័យ ៦៤.៥២៨ ដុល្លារ

២-ឧបាសិកា **គង់ ចាន់ធី** នៅសហរដ្ឋអាមេរិក ជួយកសាងព្រះវិហារ ថវិកា ១២.៤០០ ដុល្លារ

៣-លោក **ចាន់ សោម** តំណាងអង្គការ CESVI ជួយកសាងប៉ុស្តិ៍សុខភាព ពេជ្រចង្វារ ស្រុកបរិបូណ៌ ចំណាយអស់ទឹកប្រាក់ ចំនួន ១០.០០០ ដុល្លារ

៤-លោក LUIGI D'AQUINO តំណាងអង្គការ CESVI ជួយកសាងប៉ុស្តិ៍សុខភាព ពេជ្រចង្វារ ស្រុកបរិបូណ៌ ចំណាយអស់ទឹកប្រាក់ ចំនួន ១២.១៩១ ដុល្លារ

**ខ.មេដាយប្រាក់ស្ថាបនាជាតិ :**

១-ឧបាសក **ឈុយ ម៉ៃ** សមាជិកគណៈកម្មការសាងសង់ ជួយកសាងព្រះវិហារ ថវិកា ៥.០០០ ដុល្លារ

២-ឧបាសក **គីម អៀង** ប្រធានគណៈកម្មការសាងសង់ ជួយកសាងព្រះវិហារ ថវិកា ៥.០០០ ដុល្លារ

៣-ឧបាសិកា **លី អេង** នៅសហរដ្ឋអាមេរិក ជួយកសាងព្រះវិហារ ថវិកា ៦.៤០០ ដុល្លារ

**គ-មេដាយសេវត្ថស្ពាមនាជាតិ :**

-ឧបាសក **ព្រាប យ៉ាត់** អាចារ្យ វត្តឧទុម្ពរ ជួយកសាងព្រះវិហារ ថវិកា ៣.០០០ ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៩៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៣៧

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា

## សម្រេច

**មាត្រា១ៈ** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនជប៉ុន ០២រូប ដែលបានបរិច្ចាគថវិកា ចំនួន ៣៥.៨៩២ ដុល្លារ សំរាប់ជួយសាងសង់អគារសិក្សា ០១ខ្នង មាន០៦បន្ទប់ បំពាក់ដោយសម្ភារីមសិក្សាគ្រប់ប្រភេទ រួមទាំងអណ្តូងទឹក ខ្លោងទ្វារ និងកៅអីថ្ម នៅសាលាបឋមសិក្សាប្រាសាទគោកចក ឃុំគោកចក ស្រុកសៀមរាប ខេត្តសៀមរាប ដូចមានរាយនាមខាងក្រោម :-

១-លោក HAGIO TOSHIO តំណាងក្រុម *ខូបេយូ ម៉ិណិត*

២-លោក YASUI TOSHIHIKO តំណាងរាស្ត្រក្រុម *ខូបេ*

**មាត្រា២ៈ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា និង អភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួលៈ**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

SR.119

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ......................អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៚

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក ENRICO SALA ជនជាតិស្វីស ដែលបានផ្តល់ថវិកាចំនួន ៥៥.០០០ ដុល្លារ សំរាប់ជួយសាងសង់អគារសិក្សា ០២ខ្នង មាន០៩បន្ទប់ បណ្ណាល័យ ០១ខ្នង បំពាក់ដោយសម្ភារីមគ្រប់ប្រភេទ និង បង្គន់អនាម័យ នៅសាលាបឋមសិក្សាមុខនាគ ក្នុងឃុំគោកចក ស្រុកសៀមរាប ខេត្តសៀមរាប ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា និង អភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួលៈ**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

SR.121

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ ៦៣៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការ តែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការ បង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

**សម្រេច**

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន៣០៦រូប នៃក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច ដូចមានរាយនាមខាងក្រោមនេះ :-

**ក.មេដាយមាសការងារ :**

| | | | | |
|---|---|---|---|---|
